ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣ ❀ ៧៧

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ៥១៧ សជណ ធទឧ

# សេចក្ដីជូនដំណឹង

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការសង្កេត និងតាមដានលើស្ថានភាពអាកាសធាតុរួចមក ឃើញថា : ជ្រលងសម្ពាធទាបដែលបានគ្របដណ្ដប់លើជ្រោយឥណ្ឌូចិនចាប់ពីថ្ងៃទី 05 ខែកញ្ញា មកនោះ បាន និងកំពុងបង្កើនឥទ្ធិពលមកលើព្រះរាជាណាចក្រកម្ពុជា និងអាចបង្កឱ្យមានភ្លៀងធ្លាក់ច្រើនជាបន្តបន្ទាប់ ក្នុងក្របខណ្ឌទូទាំងប្រទេស ចាប់ពីថ្ងៃទី 09 ដល់ថ្ងៃទី 11 ខែកញ្ញា ឆ្នាំ 2011 ពិសេស តំបន់វាលទំនាបកណ្ដាលដែលមានភូមិសាស្ត្រជាប់នឹងជួរភ្នំ , តំបន់ភ្នំ , តំបន់ខ្ពង់រាប និងតំបន់មាត់សមុទ្រ មានជាអាទិ៍ : រាជធានីភ្នំពេញ ខេត្តកណ្ដាល កំពង់ស្ពឺ តាកែវ ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ស្ទឹងត្រែង ក្រចេះ កំពង់ចាម កំពត កោះកុង កែប និងខេត្តព្រះសីហនុ ។ ផ្ទៃសមុទ្រកម្ពុជា នឹងមានរលកខ្លាំង និងអាចមានកំពស់ពី 1,50 m ទៅ 2,00 m ។

យោងតាមសភាពការណ៍ធាតុអាកាសខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់អាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅតាមបណ្ដារាជធានី-ខេត្ត ដូចបានជម្រាបជូនខាងលើ ពិសេសបងប្អូនប្រជានេសាទសមុទ្រ សូម **បង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់** ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។/.

រាជធានីភ្នំពេញ ,ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១១

**រដ្ឋមន្ត្រី**

**លឹម គានហោ**